ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងតំបន់សហគមន៍នេសាទ

# កោះហិប

## រយៈពេល ៣ ឆ្នាំ (២០២០ - ២០២២)

ឈ្មោះសហគមន៍នេសាទ ៖ កោះហិប
ភូមិ ៖ កោះហិប
ឃុំ ៖ អូរស្វាយ
ស្រុក ៖ បុរីអូរស្វាយសែនជ័យ
ខេត្ត ៖ ស្ទឹងត្រែង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កោះហិប
# រយៈពេល ៣ ឆ្នាំ( ២០២០ - ២០២២ )

| | |
|---|---|
| សហគមន៍នេសាទ | ៖ កោះហិប |
| ភូមិ | ៖ កោះហិប |
| ឃុំ | ៖ អូរស្វាយ |
| ស្រុក | ៖ បុរីអូរស្វាយសែនជ័យ |
| ខេត្ត | ៖ ស្ទឹងត្រែង |

ខែមករា ឆ្នាំ២០១៩

# មាតិកា


**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម** ........ ២

ក.ប្រជាពលរដ្ឋ ........ ២

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ២

ក.ទីតាំង ........ ២

ខ. ដែននេសាទ ........ ៣

គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ.ធនធានជលផល ........ ៤

ឃ.១.ប្រភេទត្រី៖ ........ ៤

ឃ.២.ប្រភេទវារីសត្វ៖ ........ ៤

ឃ.៣.ប្រភេទសត្វបក្សី ........ ៤

ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៥

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនវិស័យ ........ ៦

ខ. គោលបំណងរួម ........ ៦

គ.គោលបំណងជាក់លាក់ ........ ៦

ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៦

ឃ.១.ធនធានជលផល និងអេកូឡូស៊ី ........ ៦

ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៦

ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ........ ៧

ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស ........ ៧

ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក ........ ៧

ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ ........ ៨

ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល ........ ៨

ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ៩

ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ........ ៩

ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ ........ ៩
ឃ.៣. ការងារគ្រប់គ្រង ........ ១០
ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ........ ១០
ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ ........ ១០
ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ........ ១០
ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ១១
ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ........ ១១
ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១២
ការតាមដាន ត្រួពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖ ........ ១២
ច.យុទ្ធសាស្រ្ត ........ ១២
**តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ភូមិ ទន្សោង រយៈពេល៣ឆ្នាំ (២០១៩ ដល់ ២០២២)** ........ ១៣
**តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ( តុលា ២០១៩- កញ្ញា ២០២២)** ........ ១៨

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទកោះហិប ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូងនៅឆ្នាំ២០០៦ និង បានចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍លើកទី២ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ រយៈពេល៣ឆ្នាំ គឺចាប់ពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១។ សហគមន៍នេសាទនេះ មានទីតាំងស្ថិតនៅក្នុងភូមិកោះហិប ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ដែលមានសមាជិកសរុបចំនួន៣១០នាក់ ស្រីចំនួន១៣០នាក់ ស្មើនឹង ១១០គ្រួសារ និងមានគណៈកម្មការចំនួន០៧នាក់ ស្រីចំនួន០១នាក់។ សហគមន៍នេសាទកោះហិប ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយប្រកាសលេខ ៦២៨ ប្រក.កសក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

បន្ទាប់ពីបានបោះឆ្នោតជ្រើសរើសគណៈកម្មការរួចមកសហគមន៍នេសាទនេះ បានអនុវត្តសកម្មភាពសំខាន់ៗ មានដូចជាការរៀបចំបញ្ជីឈ្មោះ និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ ធ្វើបច្ចុប្បន្នភាព និងរៀបចំបញ្ជីឈ្មោះសមាជិក លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ចូលរួមកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ រៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ រៀបចំក្រុមល្បាត ព្រមទាំងចូលរួមប្រជុំ វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាផ្សេងៗ។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានដូចខាងលើ សហគមន៍នេសាទ បានជួបប្រទះបញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផលនិងអេកូឡូស៊ី ជីវភាពប្រជាពលរដ្ឋ និងការគ្រប់គ្រងគឺ៖

-បញ្ហាប្រឈមពាក់ព័ន្ធនឹងធនធានជលផល និងអេកូឡូស៊ី រួមមាន ការកាប់បំផ្លាញព្រៃលិចទឹក នាំឱ្យបាត់បង់ព្រៃលិចទឹកជាច្រើន ត្រីថយចុះគ្រប់ប្រភេទ ការនេសាទនៅរដូវត្រីពងកូន បាក់ច្រាំងមាត់ទន្លេ និងកំណើនអ្នកនេសាទ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងជីវភាពប្រជាពលរដ្ឋរួមមាន ប្រជាពលរដ្ឋខ្វះមុខរបរចិញ្ចឹមជីវិត កំណើនប្រជាពលរដ្ឋ ខ្វះប្រភពទឹកធ្វើស្រែ ខ្វះចំណេះដឹងនិងជំនាញបច្ចេកទេសចិញ្ចឹមសត្វ ដាំដំណាំ តម្លៃផល ផលិតផលមិនស្ថិតស្ថេរ និងទីផ្សារនៅឆ្ងាយពីភូមិ

-បញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងរួមមាន ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ប្រើប្រាស់ឧបករណ៍ឆក់ និងសារជាតិពុល ប្រជាពលរដ្ឋមិនហ៊ានរាយការណ៍ពេលឃើញបទល្មើស កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធមិនទាន់រលូន មិនសូវមានការលើកទឹកចិត្តដល់គណកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋមិនយល់ពីសារៈប្រយោជន៍នៃសហគមន៍នេសាទ ខ្វះមធ្យោបាយចុះល្បាត និងថវិកា គ្មានទីស្នាក់ការសហគមន៍សម្រាប់ប្រតិបត្តិការ គណៈកម្មការសហគមន៍នេសាទពុំទាន់ស្គាល់ពីតួនាទីរបស់ខ្លួន ហើយគណៈកម្មការសហគមន៍នេសាទ និងប្រជាជនមិនទាន់យល់ពីច្បាប់ស្តីពីជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ សមាជិកសហគមន៍យល់ថាការងាររបស់គណៈកម្មការជាតួនាទីរបស់បុរស ចំណែកស្រីមានតួនាទីជាអ្នកថែទាំគ្រួសារ ធ្វើការងារផ្ទះ និងលក់ដូរប៉ុណ្ណោះ ហើយទោះបីមានស្ត្រីច្រើនចូលរួមក្នុងកិច្ចប្រជុំនានា ប៉ុន្តែការសម្រេចចិត្តរបស់ស្ត្រីនៅមានកម្រិត ។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

ចំនួនប្រជាពលរដ្ឋក្នុងភូមិកោះហិប សរុប៤៧៩នាក់ ស្រី២៤០នាក់ ស្មើ១១៨គ្រួសារ ក្នុងនោះមានជនជាតិខ្មែរចំនួន១០០%។ ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធមាន១០០%។

ប្រជាពលរដ្ឋក្នុងភូមិកោះហិប មានស្ថានភាពដូចខាងក្រោម៖

- ចំនួនស្ត្រីជាមេគ្រួសារ/ស្ត្រីមេម៉ាយមាន៥នាក់
- កម្រិតសិក្សាអប់រំមាន អ្នកមិនចេះអក្សរមានចំនួន៨៩នាក់ ស្រី៦៩នាក់ កម្រិតថ្នាក់បឋមសិក្សាចំនួន១១២ នាក់ ស្ត្រី៥៥នាក់ កម្រិតអនុវិទ្យាល័យចំនួន០៤នាក់/ស្រី ០៤ នាក់ វិទ្យាល័យចំនួន ១ នាក់/ស្រី១នាក់។

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

- អ្នកដែលមានមុខរបរនេសាទជាលក្ខណៈគ្រួសារចំនួន១៩គ្រួសារ
- អ្នកធ្វើស្រែចំនួន១៨២នាក់ ៩៧ នាក់ស្រី ដែលមានទំហំដីចំនួនសរុប ៦៤ ហិកតា
- ធ្វើចំការចំនួន១៨២ នាក់ ៩៧ នាក់/ស្ត្រី ដែលមានទំហំដីចំនួនសរុប១២ហិកតា (ស្រូវ.ពោត.ល្ង...)
- ដាំបន្លែជាលក្ខណៈគ្រួសារ៨១គ្រួសារ ដែលមានទំហំសរុប ២ហិកតា
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០០%នៃ ៩៩ គ្រួសារក្នុងភូមិទាំងអស់
- ជាងផ្ទះ ០៣គ្រួសារ
- លក់ដូរជាអាជីពចំនួន ០៩ គ្រួសារ
- ចិញ្ចឹមសត្វលក្ខណៈគ្រួសារ ១០៧ គ្រួសារ ស្មើ ៨៥%
- ជាងទូក ០៥ គ្រួសារ
- ចំណាកស្រុកទៅក្រៅប្រទេស ១ នាក់ ស្ត្រី១នាក់
- កែច្នៃផលនេសាទជាលក្ខណៈគ្រួសារចំនួន៩៩ គ្រួសារ ក្នុងនោះរួមមានប្រហុក ត្រីប្រៃ (មួយគ្រួសារអាចផលិតបានពី២០ គីឡូក្រាមទៅ ៥០គីឡូក្រាមក្នុង១ឆ្នាំ) ។

## ៣.តំបន់នេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងតំបន់នេសាទសហគមន៍

### ក.ទីតាំង

តំបន់នេសាទសហគមន៍កោះហិប ជាដែននេសាទសាធារណៈរបស់រដ្ឋ តំបន់នេសាទសហគមន៍កោះហិប មានទំហំ ១.១២៩ ហិកតា និងមានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

**មានព្រំប្រទល់៖**

- ខាងជើងទល់នឹង ពាក់កណ្តាលទន្លេសហគមន៍នេសាទវ៉ឺនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ
- ខាងត្បូងទល់នឹង សហគមន៍នេសាទកោះគី ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
- ខាងកើតទល់នឹង សហគមន៍នេសាទវ៉ឺនសៀន ឃុំអូរស្វាយ ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង
- ខាងលិចទល់នឹង សហគមន៍នេសាទជាំធំ ឃុំកោះស្នែង ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង និងសហគមន៍នេសាទក្រឡាពាល ឃុំព្រះរំកិល ស្រុកបុរីអូរស្វាយសែនជ័យ ខេត្តស្ទឹងត្រែង ។

**ខ. ដែននេសាទ**

កន្លែងសហគមន៍នេសាទកោះហិបមានវិសាលភាពនៅក្នុងទន្លេមេគង្គ ហើយមានអូរចំនួន០១ កោះចំនួន០២ និងអន្លង់ចំនួន០១។

**ខ.១.ទន្លេ**

| ឈ្មោះទន្លេ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| ទន្លេមេគង្គ | ៩.៥០០ | ពេញមួយឆ្នាំ |

**ខ.២.អូរ**

| ឈ្មោះអូរ | ប្រវែង (ម៉ែត្រ) | រដូវនេសាទ |
|---|---|---|
| អូរជ្រៃ | ១.០០០ | រដូវវស្សា |

**ខ.៣.កោះ**

| ឈ្មោះកោះ | ទទឹង និងបណ្តោយ(ម៉ែត្រ) | ទំហំសរុប (ហិកតា) |
|---|---|---|
| កោះតាហឿង | ៣០ × ១៥០ | ០,៤៥ |
| កោះឫស្សីធំ | ៥០០ × ២.០០០ | ១០ |

**ខ.៤.អន្លង់**

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវវស្សា (ម៉ែត្រ) |
| អន្លង់ទឹកវិល | ប: ៥០ × ទ: ៥០ | ២.៥០០ | ៥០ | ៤០ |
| អន្លង់អូរជ្រៃ | ប: ៣០០ × ទ: ១០០ | ៣០.០០០ | ៣០ | ២០ |
| អន្លង់ស្វាយ | ប: ២០០ × ទ: ១៥០ | ៣០.០០០ | ៣០ | ២០ |

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្សចំនួន១ អន្លង់ គឺអន្លង់អូរជ្រៃ តាមការសម្រេចរបស់សន្និបាតប្រចាំឆ្នាំរបស់សហគមន៍នេសាទកោះហិប។

| ឈ្មោះអន្លង់ | ទទឹង និងបណ្តោយ (ម៉ែត្រ) | សរុប (ម៉ែត្រក្រឡា) | ជម្រៅ | |
|---|---|---|---|---|
| | | | រដូវវស្សា (ម៉ែត្រ) | រដូវប្រាំង (ម៉ែត្រ) |
| អន្លង់អូរជ្រៃ (អន្លង់កំបោរ) | ប: ១០០ x ទ:៣០០ | ៣០.០០០ | ៣០ | ២០ |

**ឃ.ធនធានជលផល**

**ឃ.១.ប្រភេទត្រី៖**

ត្រីរ៉ស់ ឆ្តោរ រៀល ស្លាត ឆ្លាំង ក្រម៉ម អណ្តែង ច្រវ៉ា កំភ្លាញ ឆ្លូញ ខ្មាន់ ឆ្ពិន ប្រកែង កន្ទ្រប់ ត្រីដំរី កញ្ចុះ ក្រុះ កញ្ច្រូក កាហែរ លិញ ទ្រនេល សណ្តាយ ក្រាយ ព្រលូង ត្រីស្លឹកឫស្សី ត្រីខ្ទឹង ត្រីខ្យា ត្រីកេះ ឆ្តោក ត្រីកែ ត្រីក្រសក់ ត្រីគល់រាំង ត្រីអណ្តែង ត្រីក្អែក ត្រីថ្ម ត្រីចិន ត្រីបបែល ត្រីពោ ត្រីចេកទុំ ត្រីក្លាំងហាយ ត្រីឆ្មា ត្រីរាហ៊ូ ត្រីក្របី ត្រីកន្ទ្រង់ប្រេង ត្រីឫស្សីចេក ត្រីក្ដុក ត្រីគ្រំ ត្រីកំបុតច្រមុះ ត្រីខ្យាថ្ម ត្រីប៉ាសុីអុី ត្រីប៉ាវ៉ា ត្រីអន្លុង ត្រីអាចម៍កុក....។

**ឃ.២.ប្រភេទវារីសត្វ៖**

ក្តាម ខ្យង់ ខ្ចៅ គ្រុម លៀស ពស់ កំពិស កង្កែប ហុីង គីង្គក់...។

**ឃ.៣.ប្រភេទសត្វបក្សី**

កុកស កុកក្រក មាន់ទឹក ប្រវឹក ទាព្រៃ រនាលខ្យង ក្អែកទឹក ក្អែកគោក...។

**ឃ.៤.ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ៖**

ដើមត្រែង ដើមអញ្ចែង ដើមរំចេក ដើមអណ្តែង ដើមក្រស់ ដើមរាំង ដើមល្វា ដើមផ្កាទឹក ដើមក្តុល ដើមជ្រៃ....។

## ៤.ការធ្វើនេសាទ

**ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន៦៣គ្រួសារ ស្មើ១៤៩នាក់ ស្រី៨០នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន២០នាក់/ស្រី០៤ នាក់
- អ្នកនេសាទមកពីក្រៅសហគមន៍មានចំនួន ២៥នាក់ ស្ត្រី៨នាក់។

**ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកការណូតរបស់សមាជិកសហគមន៍នេសាទ អ្នកមិនចូលជាសមាជិក និងអ្នកនេសាទមកពីក្រៅសហគមន៍៖

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | | | ទំហំ /ប្រវែង | | | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|---|---|---|---|
| | | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | |
| មង | ម៉ែត្រ | ១១០គ្រួសារ× ១០០ម = ១១.០០០ម | គ្មាន | ១២គ្រួសារ× ៥០០ម= ៦.០០០ម | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | គ្មាន | ក្រឡា២-១២ ស.មជម្រៅ ៣-៥ម | ពេញមួយឆ្នាំ |
| សំណាញ់ | វង់ | ១១០គ្រួសារ× ១វង់=១១០វង់ | គ្មាន | គ្មាន | ក្រឡា១,៥-៧ ស.មសំរុង ៣,៥ -៥.៥ម | គ្មាន | គ្មាន | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ១១០គ្រួសារ× ១០០ផ្លែ = ១១,០០០ផ្លែ | គ្មាន | ៨គ្រួសារ× ៤០០ផ្លែ =៣២០០ផ្លែ | ផ្លែលេខ ១២-៥ | គ្មាន | ផ្លែលេខ ១២-៥ | ពេញមួយឆ្នាំ |
| លប | គ្រឿង | ១០គ្រួសារ × | គ្មាន | គ្មាន | មុខកាត់០,៣ | គ្មាន | គ្មាន | វស្សា |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | ៥គ្រឿង =៥០គ្រឿង | | | ម ប្រវែង១ម | | | |
| ចាន់ | គ្រឿង | ១៥គ្រួសារ×៥ គ្រឿង=៧៥ គ្រឿង | គ្មាន | គ្មាន | មុខកាត់ ៤០ស.ម ប្រវែង១,៣ម | គ្មាន | គ្មាន | វស្សា |

### ប្រភេទទូកកាណូត

| ប្រភេទកាណូត | ចំនួន (គ្រឿង) | | | ចំណុះ (គីឡូក្រាម) | | | កំលាំង (សេះ) | | |
|---|---|---|---|---|---|---|---|---|---|
| | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ | សមាជិក | មិនមែនសមាជិក | អ្នកខាងក្រៅភូមិ |
| ទូកអេរវជាប់ម៉ាស៊ីន HONDA / HINOTA | ៥ | ៣ | ០ | ២០០-៣០០ | ៣០០-៤០០ | ០ | ៥.៥ | ៩ | ០ |
| ទូកអេរវជាប់ម៉ាស៊ីន HONDA | ២៥ | ១២ | ០ | ២០០-៣០០ | ២០០-៣០០ | ០ | ៦.៥០ | ៦.៥០ | ០ |
| ទូកអេរវជាប់ម៉ាស៊ីន HONDA | ២ | ០ | ០ | ៣០០-៤០០ | ០ | ០ | ៨ | ០ | ០ |
| ទូកអេរវជាប់ម៉ាស៊ីន HONDA | ៣ | ០ | ០ | ៣០០-៤០០ | ០ | ០ | ៩ | ០ | ០ |
| ទូកអុំ ចែវ | ១៥ | ០ | ០ | ១០០-១៥០ | ០ | ០ | ០ | ០ | ០ |

### គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមក្នុង១គ្រួសា | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៧៤១,១៤ | ៩១៩,៩១ | ១.៦៦១,០៥ |
| **សរុប** | | | **១.៦៦១,០៥** |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទកោះហិប មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចីរភាពដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណងរួម

ដើម្បីសម្រេចបាននូវទស្សនៈវិស័យខាងលើ សហគមន៍នេសាទ មានគោលបំណងរួមដូចខាងក្រោម៖

- ធ្វើឱ្យត្រីមានការកើនឡើង
- បង្កើនប្រាក់ចំណូលដល់សមាជិកសហគមន៍នេសាទ
- បទល្មើសនេសាទមានការថយចុះ ។

### គ.គោលបំណងជាក់លាក់

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាប កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចម្រុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### ឃ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ឃ.១.ធនធានជលផល និងអេកូឡូស៊ី

### ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺគិតគូរអំពីដែននេសាទ ប្រភេទឧបករណ៍នេសាទ ទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ក្នុងទន្លេមេគង្គកន្លែងនេសាទសហគមន៍កោះហិប | នេសាទពេញ១ឆ្នាំជាលក្ខណៈគ្រួសារ | មង | ១០០ម៉ែត្រ/គ្រួសារ | ១០០ គ្រួសារ | សមាជិកសហគមន៍អ្នកនេសាទខាងក្រៅ |
| | | សំណាញ់ | ១វង់/គ្រួសារ | ១១០គ្រួសារ | |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ១១០គ្រួសារ | |
| | | លប | ៥គ្រឿង/គ្រួសារ | ១០គ្រួសារ | |
| | | ចាន់ | ៥គ្រឿង/គ្រួសារ | ១៥គ្រួសារ | |
| អូរជ្រៃ | ខែ០៨ ដល់ខែ១០ | មង | ១០០ម៉ែត្រ/គ្រួសារ | ១០០ គ្រួសារ | សមាជិកសហគមន៍នេសាទកោះហិប |
| | | សំណាញ់ | ១វង់/គ្រួសារ | ១១០គ្រួសារ | |
| | | សន្ទូច | ១០០ផ្លែ/គ្រួសារ | ១១០គ្រួសារ | |
| | | លប | ៥គ្រឿង/គ្រួសារ | ១០គ្រួសារ | |

### ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ

ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះផែនទេសាទ | ទំហំ/ចំនួន | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | អ្នកទទួលខុសត្រូវ | ពេលវេលា | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្ដើម | បញ្ចប់ |
| កន្លែងនេសាទសហគមន៍កោះហិប | បង្គោលព្រំធ្វើពីស៊ីម៉ងត៍ចំនួន៤បង្គោល | - ផលិតបង្គោលព្រំ<br>- រៀបចំក្រុមចុះបោះបង្គោលព្រំ | ២០០ | គណៈកម្មការសមាជិកមេភូមិ | ២០២០ | ២០២២ |
| | ផ្ទាំងប៉ាណូផែនទីធ្វើពីដែក១ផ្ទាំង | - ផលិតផ្ទាំងប៉ាណូផែនទី<br>- ចុះបោះផ្ទាំងប៉ាណូផែនទី | ២៥០ | គណៈកម្មការសមាជិក | ២០២០ | ២០២២ |

### ឃ.១.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការរៀបចំកន្លែងអភិរក្ស ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ (ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| អន្លង់អូរជ្រៃ | ៣ ហិកតា | - ត្រីមេពូជ<br>- សត្វស្លាប<br>- ព្រៃលិចទឹក | - ផ្សព្វផ្សាយពីកន្លែងអភិរក្សដល់សមាជិក<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ស្លាកអប់រំចំនួន៣០ស្លាក<br>- ចុះល្បាតការពារជាប្រចាំ | ៤៥០ | ២០២០ | ២០២២ |

### ឃ.១.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹក ត្រូវបានរៀបចំដូចខាងក្រោម៖

| ឈ្មោះ/ទីតាំង | ទំហំ (ហិកតា) | ប្រភេទកូនឈើត្រូវការពារ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|---|
| នៅក្នុងកន្លែងសហគមន៍នេសាទកោះហិប | ៥០ | ព្រៃលិចទឹកចម្រុះ | - ធ្វើផែនការដាំព្រៃលិចទឹក<br>- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ១.២០០ | ២០២០ | ២០២២ |

**ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ**

**ឃ.២.១. ផែនការមុខរបរបង្កើនប្រាក់ចំណូល**

ផែនការមុខរបរបង្កើនប្រាក់ចំណូល ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ប្រភេទ/បរិមាណ | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំប្រមូលផល |
|---|---|---|---|---|---|
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន២០គ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសកសិករស្ម័គ្រចិត្ត<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | ពូជក្នុងស្រុក១គ្រួសារទទួលបានមាន់១០ក្បាល សរុប២០០ក្បាល | ៣.០០០ | ២០២០ | ២០២២ |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន២០គ្រួសារ | - ប្រជុំផ្សព្វផ្សាយ ជ្រើសរើសកសិករ<br>- រៀបចំទ្រុងសម្រាប់ចិញ្ចឹម<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- រកទិញពូជ និងដាក់ពូជចិញ្ចឹម<br>- តាមដានត្រួតពិនិត្យការថែទាំ | កូនជ្រូកពូជ ២០ ក្បាល | ៤.៨០០ | ២០២០ | ២០២២ |
| ១៥គ្រួសារបង្កើតធនាគារក្របី | -ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- បង្កើតគោលការណ៍ក្រុម<br>- តាមដានត្រួតពិនិត្យការថែទាំ | ២ក្បាល/៥ គ្រួសារ | ៣.០០០ | ២០២០ | ២០២២ |
| បង្កើតក្រុមសន្សំប្រាក់ ១ក្រុមមានសមាជិក ៤៥នាក់ | - ផ្សព្វផ្សាយទស្សនៈក្រុមសន្សំ<br>- បោះឆ្នោតជ្រើសរើសប្រធាន, អនុប្រធាន លេខា នឹងហិរញ្ញិក<br>- បង្កើតគោលការណ៍និងបទបញ្ញាផ្ទៃក្នុងរបស់ក្រុមសន្សំប្រាក់<br>- ត្រួតពិនិត្យតាមដាន | | ១.៥០០ | ២០២០ | ២០២២ |

### ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | បរិមាណ កូនត្រី | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | បញ្ចប់ |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសលក្ខណៈគ្រួសារ (២០គ្រួសារ/ឆ្នាំ) | - ប្រជុំផ្សព្វផ្សាយជ្រើសរើសកសិករ<br>- រៀបចំស្រះ ដាក់កូនត្រី<br>- បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម<br>- ត្រួតពិនិត្យ ធ្វើសំណាក<br>- ស្វែងរកទីផ្សារលក់ត្រី | ២៥ស្រះ ទំហំ ៥ម×១០ម | ២៥.០០០ | ១០.០០០ | ២០២០ | ២០២២ |

### ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា (ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|
| ផ្តល់ប្រព័ន្ធអគ្គីសនីពន្លឺព្រះអាទិត្យក្នុងសហគមន៍ចំនួន៥០គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |
| សាងសង់បង្គន់អនាម័យ ៥០គ្រួសារ | ៧.៥០០ | ២០២០ | ២០២២ |
| ផ្តល់ធុងចម្រោះទឹក១១០គ្រួសារ | ៥.៥០០ | ២០២០ | ២០២២ |

### ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ

ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | សកម្មភាព | ប៉ាន់ប្រមាណ តម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ផែនការបង្ការ និងបន្សាំភាពធន់ និងការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការ | ៣០០ | ២០២០ | ២០២២ |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | ១០០ | ២០២០ | ២០២២ |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | ៥០ | ២០២០ | ២០២២ |
| | វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងអាជ្ញាធរ | ១០០ | ២០២០ | ២០២២ |
| | ចងក្រងបណ្តាញគណៈកម្មការគ្រោះមហន្តរាយតាមភូមិ | ៥០ | ២០២០ | ២០២២ |

### ឃ.៣. ការងារគ្រប់គ្រង

#### ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស

ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| សហគមន៍នេសាទចុះល្បាតដោយខ្លួនឯង | ៣ដង/១ខែ | ១.០៨០ | ២០២០ | ២០២២ |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរ មូលដ្ឋានដើម្បីទប់ស្កាត់បទល្មើសមកពីក្រៅ | ២ដង/១ខែ | ៧៥០ | ២០២០ | ២០២២ |
| ទិញទូកស្ពាច់ម៉ាស៊ីន (១៣សេះ) | ១ គ្រឿង | ១.២០០ | ២០២០ | ២០២២ |
| សាងសង់ទីស្នាក់ការសហគមន៍ទំហំ ៤ម×៥ម | ១ ខ្នង | ៥០០ | ២០២០ | ២០២២ |

#### ឃ.៣.២.ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ

ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួន | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| រៀបចំប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | ៣៦ដង/១ឆ្នាំ | ៣៦០ | ២០២០ | ២០២២ |
| ចូលរួមប្រជុំប្រចាំខែ ឬត្រីមាស ជាមួយក្រុមប្រឹក្សាឃុំ | ៣៦ដង/១ឆ្នាំ | ១៨០ | | |
| បណ្ដុះបណ្ដាលការរៀមចំរបាយការណ៍ កំណត់ហេតុ | ១ដង/១ឆ្នាំ | ២០០ | | |
| បណ្ដុះបណ្ដាលការគ្រប់គ្រងថវិកា | ១ដង/១ឆ្នាំ | ២៥០ | | |
| បណ្ដុះបណ្ដាលសរសេរគម្រោងសំណើរ | ១ដង/១ឆ្នាំ | ២៥០ | | |

#### ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ

ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ចំនួនដង | ប៉ាន់ប្រមាណតម្លៃ(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |
| ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃធនធានជលផល | ១/១ឆ្នាំ | ៣០០ | ២០២០ | ២០២២ |
| ច្បាប់ស្ដីពីជលផលស្ដីពីតំបន់ការពារធនធានធម្មជាតិបទដ្ឋានបច្ចេកទេសពាក់ព័ន្ធ | ២/១ឆ្នាំ | ៦០០ | ២០២០ | ២០២២ |

**ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | ៣០០ | ២០២០ | ២០២២ | - គណៈកម្មាការ<br>- អាជ្ញាធរឃុំ |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងកម្មវិធីវិនិយោគឃុំ | | ២០២០ | ២០២២ | |

**ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ ត្រូវបានរៀបចំដូចខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្ដើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍នេសាទ | ប្រមូលភាគទាន៥០០រៀល/ម្នាក់ | ២០២០ | ២០២២ | ៣៨,៧៥ | |
| ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំចំនួន ២.០០០/គ្រួសារ នៃសមាជិកសរុប ១១០ គ្រួសារ | ២០២០ | ២០២២ | ១៦៥ | |
| ភាគទានពីអ្នកនេសាទក្រៅសហគមន៍នេសាទ | ប្រមូលប្រាក់ភាគទានពីអ្នកនេសាទខាងក្រៅ ២៥នាក់ (៥០.០០០រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៩៣៧,៥ | |
| | ប្រមូលប្រាក់អ្នកមិនមែនជាសមាជិកសហគមន៍នេសា២០នាក់ (៥.០០០ រៀល/ទូក/រដូវនេសាទ) | ២០២០ | ២០២២ | ៧៥ | |
| **សរុបថវិកាដែលសហគមន៍មាន** | | | | **១.២១៦** | |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | • បញ្ចូលផែនការអភិវឌ្ឍសហគមន៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ<br>• ទំនាក់ទំនងជាមួយស្ថាប័នជលផល<br>• សរសេរគម្រោងស្នើសុំពីអង្គការដៃគូ | ២០២០ | ២០២២ | **៦៩.០៣៣** | |
| **សរុបចំណាយ** | | | | **៦២.៧១៦** | |

### ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានរៀបចំដូចខាងក្រោម៖

| សកម្មភាព | ប៉ាន់ប្រមាណថវិកា(ដុល្លារ) | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច | ១០០ | ២០២០ | ២០២២ | -គណៈកម្មការ<br>-អាជ្ញាធរឃុំ |

### ច.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យយុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមានសមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ សមាជិកសហគមន៍នេសាទ ដែលមានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណា ដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី និងការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការដៃគូ គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗឱ្យបានជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជំរុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀរគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍នេសាទ
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះហិបរយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្ដើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| **ឃ.១.ធនធានជលផល និងអេកូឡូស៊ី** | | | | | | | |
| ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ | ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាតទំហំ ពេលវេលា និងទីកន្លែងនេសា ទនិងប្រភេទឧបករណ៍នេសាទហាមឃាត់ | ផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានផ្សព្វផ្សាយ២ដង ក្នុង១ឆ្នាំ (រដូវបិទ និងបើកនេសាទ) | ៦០០<br>១ដង×១០០×២លើក×៣ឆ្នាំ= | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.២.ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ | ផលិតបង្គោលព្រំធ្វើពីស៊ីម៉ង់ត៍ចំនួន៤ បង្គោលដាក់នៅតាមព្រំប្រទល់ដែននេសាទកោះហិប | - បង្គោលចំនួន៤ដើមត្រូវបានផលិត និងបានបោះនៅតាមព្រំប្រទល់<br>- កាត់បន្ថយបាននូវទំនាស់ព្រំប្រទល់ | ៤០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ដំឡើងផ្ទាំងប៉ាណូផែនទីចំនួន១ផ្ទាំង | ផ្ទាំងប៉ាណូផែនទីចំនួន១ផ្ទាំងបានផលិត និងបានបោះនៅក្នុងសហគមន៍ | ២៥០ | | ២០២០ | ២០២២ | |
| ឃ.១.៣.ការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់អូរជ្រៃ | - ផ្សព្វផ្សាយពីកន្លែងអភិរក្ស និងសារៈប្រយោជន៍កន្លែងអភិរក្ស<br>- បោះទង់សំគាល់ព្រំតំបន់អភិរក្ស<br>- ដាក់ផ្លាកនៅអន្លង់អភិរក្ស<br>- ដាក់ផ្លាកប៉ាណូផែនទីអន្លង់អភិរក្ស<br>- ចុះល្បាតការពារជាប្រចាំ | - ត្រី និងសត្វគ្រប់ប្រភេទ នឹងសំបូរឡើងវិញនៅក្នុងតំបន់សហគមន៍<br>-ប្រជាជនយល់ដឹងពីសារៈប្រយោជន៍កន្លែងអភិរក្ស និងបានដឹងពីព្រំប្រទល់កន្លែងអភិរក្ស | ៤៥០ | -សហគមន៍នេសាទ<br>-រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| ឃ.១.៤.ផែនការគ្រប់គ្រងការពារព្រៃលិចទឹក | - ធ្វើផែនការដាំព្រៃលិចទឹក<br>- ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈប្រយោជន៍ព្រៃលិចទឹក<br>- ដាក់ស្លាកហាមកាប់ព្រៃលិចទឹក<br>- ថែរក្សា ការពារព្រៃលិចទឹកចម្រុះ<br>- ចុះល្បាតការពារជាប្រចាំ | ព្រៃលិចទឹកកើនឡើងវិញ<br>ធនធានត្រីមានការកើនឡើងវិញ | ១.២០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ឃ.២.ការគាំទ្រជីវភាពប្រជាពលរដ្ឋ | | | | | | | |
| ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល | ចិញ្ចឹមមាន់តាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមមាន់ចំនួន២០គ្រួសារ | ៣.០០០ | -រដ្ឋបាលជលផល<br>-អង្គការដៃគូ | ២០២០ | ២០២២ | |
| | ចិញ្ចឹមជ្រូកតាមបច្ចេកទេសលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមជ្រូកចំនួន២០គ្រួសារ | ៤.៨០០ | | ២០២០ | ២០២២ | |
| | បង្កើតធនាគារក្របី | សមាជិកចំនួន១៥គ្រួសារបានចូលរួមបង្កើតធនាគារក្របី | ៣.០០០ | | ២០២០ | ២០២២ | |
| | បង្កើតក្រុមសន្សំប្រាក់១ក្រុម | សមាជិកចំនួន៤៥គ្រួសារ បានបង្កើតអោយមានក្រុមសន្សំប្រាក់ | ១.៥០០ | | ២០២០ | ២០២២ | |
| ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | មានគ្រួសារចិញ្ចឹមត្រីអណ្តែងចំនួន២០គ្រួសារ | ១០.០០០ | -រដ្ឋបាលជលផល<br>-អង្គការនានា | ២០២០ | ២០២២ | |
| ឃ.២.៣. ផែនការសេវាសហគមន៍និងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច | ផ្តល់ប្រព័ន្ធអគ្គិសនីពន្លឺព្រះអាទិត្យក្នុងសហគមន៍ | មានសូឡាចំនួន៥០ សម្រាប់ផ្តល់ជូនសមាជិក ៥០គ្រួសារ | ៧.៥០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | សាងសង់បង្គន់អនាម័យ | មានបង្គន់អនាម័យចំនួន៥០ បានសាង សង់ជូនសមាជិក៥០គ្រួសារ | ៧.៥០០ | | ២០២០ | ២០២២ | |
| | ផ្តល់ធុងចម្រោះទឹក | មានធុងចម្រោះចំនួន១១០ធុងប្រគល់ ជូនសមាជិក១១០គ្រួសារ | ៥.៥០០ | | ២០២០ | ២០២២ | |
| ឃ.២.៤.ផែនការបង្ការ និងបន្សាំការប្រែប្រួលអាកាសធាតុ | ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួល អាកាសធាតុ និងការបង្ការ | គណៈកម្មការ និងសមាជិកមានការយល់ដឹងពីផលប៉ះពាល់ពីការប្រែប្រួលអាកាស ធាតុ និងរបៀបបង្ការ | ៣០០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | រៀបចំបង្គោលវាស់កម្ពស់ទឹក | មានបង្គោលវាស់កំពល់ទឹកចំនួន១ | ១០០ | | ២០២០ | ២០២២ | |
| | ពង្រឹងក្រុមទ្រទ្រង់គ្រោះមហន្តរាយភូមិ | គណៈកម្មការគ្រប់គ្រងគ្រោះមហន្ត | ៥០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | រាយភូមិ | | | | | |
| | ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សាំការប្រែប្រួលអាកាសធាតុ | គណៈកម្មការមានចំណេះដឹងទាក់ទងនិងការបន្សាំ ការប្រែប្រួលអាកាសធាតុ | ១០០ | | ២០២០ | ២០២២ | |
| | ចងក្រងបណ្តាញក្រុមទ្រទ្រង់គ្រោះមហន្តរាយតាមភូមិ | បានរៀបចំចងក្រងបណ្តាញគ្រោះមហន្ត រាយនៅក្នុងភូមិ | ៥០ | | ២០២០ | ២០២២ | |
| **ឃ.៣. ការគ្រប់គ្រង** | | | | | | | |
| ឃ.៣.១.ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស | សហគមន៍ចុះល្បាតដោយខ្លួនឯង | បានចុះល្បាត៣ដង/ខែ | ១.០៨០ | -រដ្ឋបាលជលផល<br>-អង្គការនានា<br>-សប្បុរសជន | ២០២០ | ២០២២ | |
| | ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើស | បានចុះល្បាត២ដង/១ខែសហការជាមួយអាជ្ញាធរមូលដ្ឋាន | ៧២០ | | ២០២០ | ២០២២ | |
| | ទិញទូកស្ទាច់ម៉ាស៊ីន (១៣សេះ) | មានទូកម៉ាស៊ីន ចំនួន១គ្រឿង | ១.២០០ | | ២០២០ | ២០២២ | |
| | សាងសង់ទីស្នាក់ការសហគមន៍ | សហគមន៍មានស្នាក់ការសម្រាប់ធ្វើការរបស់ខ្លួន | ៥០០ | | ២០២០ | ២០២២ | |
| ឃ.៣.២. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | បានប្រជុំ១ដង/១ខែ ជាមួយគណៈកម្មការ សមាជិក | ៣៦០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ចូលរួមប្រជុំប្រចាំខែជាមួយឃុំ | ចូលរួម១ដង/១ខែជាមួយឃុំ | ១៨០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការរៀមចំរបាយការណ៍ កំណត់ហេតុ | -មានវគ្គបណ្តុះបណ្តាលលើមុខជំនាញនីមួយៗ១លើក/១ឆ្នាំ | ២០០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា និងគ្រប់គ្រងបញ្ជីរស្នាម | -សមត្ថភាពសហគមន៍នេសាទបានល្អប្រសើរ | ២៥០ | | ២០២០ | ២០២២ | |
| | បណ្តុះបណ្តាលការសរសេរគម្រោងសំណើនិងភាពជាអ្នកដឹកនាំ | -គណៈកម្មការសហគមន៍នេសាទអាចអនុវត្តន៍បាន | ២៥០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| ឃ.៣.៣.ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ | ផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ<br>-សហគមន៍នេសាទ | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយកិច្ចព្រមព្រៀងសហគមន៍នេសាទ | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | ផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីជលផល | បានរៀបចំផ្សព្វផ្សាយ២ដង/ឆ្នាំ | ៦០០ | | ២០២០ | ២០២២ | |
| | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងពីសារៈប្រយោជន៍ធនធានជលផល | បានរៀបចំយុទ្ធនាការ១ដង/ឆ្នាំ | ៣០០ | | ២០២០ | ២០២២ | |
| ឃ.៣.៤.ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ | ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈបុណ្យទាន មហាសន្និបាតប្រចាំឆ្នាំ | -បានផ្សព្វផ្សាយ ២ដង/ឆ្នាំ<br>-បានបញ្ចូលសកម្មភាពផែនការគ្រប់គ្រងរបស់សហគមន៍នេសាទទៅក្នុងផែនការកម្មវិធីវិនិយោគឃុំ | ៣០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរឃុំ | ២០២០ | ២០២២ | |
| | បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅក្នុងកម្មវិធីវិនិយោគឃុំ | | | | ២០២០ | ២០២២ | |
| ឃ.៣.៥.ផែនការថវិកា ទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ | ភាគទានពីសមាជិកភាព | សមាជិកសហគមន៍បានបង់ភាគទានសមាជិកភាព | ៣៨,៧៥ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |
| | ភាគទានពីសមាជិកប្រចាំឆ្នាំ | សមាជិកសហគមន៍បានបង់ភាគទានប្រចាំឆ្នាំ១ឆ្នាំម្តង | ១៦៥ | | ២០២០ | ២០២២ | |
| | ភាគទានពីអ្នកខាងក្រៅ និងអ្នកមិនមែនជាសមាជិកសហគមន៍នេសាទ | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមកពីខាងក្រៅ | ៩៣៧ | | ២០២០ | ២០២២ | |
| | | បានទទួលប្រាក់បដិភាគពីអ្នកនេសាទមិនមែនជាសមាជិក | ៤៥០ | | ២០២០ | ២០២២ | |

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានថវិកា(ដុល្លារ) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ប្រាក់ចំណូលពីប្រភពផ្សេងៗ(ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជន) | សហគមន៍នេសាទទទួលបានកញ្ចប់ថវិកាពីប្រភពស្របច្បាប់ផ្សេងៗ | | | ២០២០ | ២០២២ | |
| ង.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ | រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំ ដោយមានការចូលរួមពីស្ត្រី និងអ្នកពាក់ព័ន្ធសំខាន់ៗ | -បានប្រជុំមហាសន្និបាត ១ដង/ឆ្នាំ<br>-ធ្វើសេចក្តីរាយការណ៍ពីលទ្ធផលការងារ និងលើកផែនការបន្ត | ៣០០ | -អង្គការដៃគូ<br>-រដ្ឋបាលជលផល<br>-អាជ្ញាធរមូលដ្ឋាន | ២០២០ | ២០២២ | |

## តារាងកម្មវិធីការងាររយៈពេល៣ឆ្នាំ (២០២០ ដល់ ២០២២)

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.១. ធនធានជលផល និងអេកូឡូស៊ី** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.១.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីប្រភេទឧបករណ៍នេសាទដែលអនុញ្ញាត ទំហំពេលវេលា និងទីកន្លែងនេសាទ និងប្រភេទឧបករណ៍នេសាទហាមឃាត់ | | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | | | × | | | | | |
| **ឃ.១.២. ផែនការបោះបង្គោលព្រំប្រទល់ និងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផលិតបង្គោលព្រំចំនួន៤បង្គោល | | | | | × | × | × | × | | | | | | | | | | | | × | × | × | × | | | | | | | | | | | | | |
| បោះបង្គោលព្រំប្រទល់ | | | | | | | | | × | × | | | | | | | | | | | | | × | × | | | | | | | | | | | | |
| តម្លើងផ្ទាំងប៉ាណូផែនទីសហគមន៍នេសាទចំនួន១ | | | | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.១.៣.ផែនការកំណត់ និងរៀបចំតំបន់អភិរក្សអន្លង់អូរជ្រៃ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីអន្លង់អភិរក្ស និងសារៈប្រយោជន៍ | | | | | | | × | | | | | | | | | × | | | | | | | | | | × | | | | | | | | | | |
| បោះទង់សម្គាល់ព្រំអន្លង់អភិរក្សចំនួន៤ទង់ | | | | | | | | | | × | | | | | | | | | | | | | | | | | | | | | | | | | | |
| ដាក់ស្លាកសញ្ញា៣០ស្លាក | | | | | | | | | | | | | | × | × | | | | | | | | | | | | | | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ដាក់ផ្លាកប៉ាណូផែនទី១ផ្ទាំង | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.១.៤. ផែនការគ្រប់គ្រង ការពារព្រៃលិចទឹក** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ធ្វើផែនការដាំព្រៃលិចទឹក | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយអោយបានទូលំទូលាយពីសារៈប្រយោជន៍ | | | | | × | | | | | | | | × | | | | | | × | | | | | | × | | | | | × | | | | | | |
| ដាក់ស្លាកសញ្ញាហាមកាប់ព្រៃលិចទឹកចំនួន១០ស្លាក | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតការពារជាប្រចាំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ឃ.២. គាំទ្រជីវភាពប្រជាពលរដ្ឋ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.១.ផែនការមុខរបរបង្កើនប្រាក់ចំណូល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមមាន់តាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | × | × | | | | |
| ចិញ្ចឹមជ្រូកតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | |
| បង្កើតធនាគារក្របី | | | | | | | | | | | | × | × | | | | | | | | | | | × | × | | | | | | | | | | | |
| បង្កើតក្រុមសន្សំប្រាក់១ក្រុម | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.២.២.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចិញ្ចឹមត្រីអណ្តែងក្នុងស្រះតាមបច្ចេកទេសជាលក្ខណៈគ្រួសារ | | | | | | | | | × | × | × | | | | | | | | | × | × | × | | | | | | | | | | | | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **ឃ.២.៣. ផែនការសេវាសហគមន៍ និងហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្តល់ប្រព័ន្ធអគ្គិសនីពន្លឺព្រះអាទិត្យក្នុងសហគមន៍ | | | | | × | × | × | × | | | | | | | | | | | | | | | × | × | × | × | | | | | | | | | | |
| សាងសង់បង្គន់អនាម័យ | | | × | × | × | | | | | | | | | | | | | × | × | × | | | | | | | | | | | | | × | × | × | |
| ផ្តល់ធុងចម្រោះទឹក | | | | | | | × | × | | | | | | | | | | | | | × | × | | | | | | | | | | × | × | | | |
| **ឃ.២.៤.ផែនការបង្ការ និងបន្សុំាការប្រែប្រួលអាកាសធាតុ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការបង្ការផ្សេងៗ | | × | × | × | | | | | | | | | | | | × | × | × | × | | | | | | | | | × | × | × | × | | | | | |
| រៀបចំបង្គោលវាស់កម្ពស់ទឹក | | | | | × | × | | | | | | | | | | | | | | | | × | × | | | | | | | | | | × | × | | |
| កំណត់រៀបចំទីទួលសុវត្ថិភាព | | | | | | | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ពង្រឹងគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងភូមិ | | | | | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការបន្សុំាការប្រែប្រួលអាកាសធាតុ | | | | | | | | × | × | × | | | | | | | | | | | | | × | × | × | | | | | | | | | | | |
| ចងក្រងបណ្តាញគណៈកម្មការគ្រោះមហន្តរាយតាមភូមិ | | | | | | | | | | | | | × | × | × | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣. ការងារគ្រប់គ្រង** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.១. ផែនការសកម្មភាពចុះល្បាតទប់ស្កាត់បទល្មើស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សហគមន៍ចុះល្បាតដោយ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ខ្លួនឯង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ចុះល្បាតដោយសហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីទប់ស្កាត់បទល្មើស | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ទិញទូកស្ពាច់ម៉ាស៊ីន | | | × | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | | | | | | |
| សាងសង់ទីស្នាក់ការសហគមន៍នេសាទ | | | | | | | | | × | × | × | × | × | | | | | | | | | | | | | | | | | | | | | | | |
| **ឃ.៣.២. ផែនការពង្រឹងគណៈកម្មការសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| បណ្តុះបណ្តាលការសរសេរគម្រោងសំណើនិងភាពជាអ្នកដឹកនាំ | | | | | | | | | | | × | | | | | | | | | × | | | | | | | | | | | | | × | | | |
| បណ្តុះបណ្តាលការរៀបចំរបាយការណ៍ កំណត់ហេតុ | | | | | | | × | | | | | | | | | | | | | | | | × | | | | | | | | | | | | × | |
| បណ្តុះបណ្តាលការគ្រប់គ្រងថវិកា និងគ្រប់គ្រងបញ្ជីរស្មាម | | | | | | | | | | × | | | | | | | | | | | | | | | | × | | | | | | | | | | × |
| **ឃ.៣.៣. ផែនការបង្កើនការយល់ដឹងដល់សមាជិកសហគមន៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយលិក្ខន្តិកៈនិងបទ | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| បញ្ហាផ្ទៃក្នុងសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយកិច្ចព្រមព្រៀង | × | | | | | | | × | | | | | | × | | | | | | × | | | | | | | × | | | | | | × | | | |
| ផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធម្មជាតិនិងច្បាប់ស្តីពីជលផល | | | | | | × | | | | | | | | × | | | | | | | × | | | | | | × | | | | | × | | | | × |
| យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងអំពីសារប្រយោជន៍ធនធានជលផល | | | | | | | × | | | | | | | | | | | | | × | | | | | | | | | | × | | | | | | |
| **ឃ.៣.៤. ការផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ទៅសមាជិកសហគមន៍តាមរយៈ បុណ្យទាន សន្និបាតប្រចាំឆ្នាំ | | | × | | | | | | | | | × | | | | | | | | | × | | | | | | | | × | | | | | | | |
| បញ្ចូលផែនការគ្រប់គ្រងកន្លែងនេសាទសហគមនទៅក្នុងកម្មវិធីវិនិយោគឃុំ | × | × | × | | | | | | | | | | × | × | × | | | | | | | | | | × | × | × | | | | | | | | × | × |
| **ឃ.៣.៥. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ភាគទានពីសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ភាគទានពីសមាជិកប្រចាំឆ្នាំ | | | | × | | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | |

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២០ | | | | | | | | | | | | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ប្រាក់បដិភាគអ្នកនេសាទខាងក្រៅសហគមន៍ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| ប្រាក់បដិភាគមិនមែនជាសមាជិកសហគមន៍នេសាទ | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × | × |
| **ប្រាក់ចំណូលពីប្រភពផ្សេងៗ** (ជំនួយពីរាជរដ្ឋាភិបាល ជំនួយពីអង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល និងអំណោយពីសប្បុរសជន) | | | | × | | | | | | | | | | | × | | | | | | | × | | | | | | | | × | | | | | | |
| **ង.ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| រៀបចំមហាសន្និបាតសហគមន៍ប្រចាំឆ្នាំដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ | | | | × | | | | | | | | | | | × | | | | | | | | | | | | × | | | | | | | | | |

លេខ......39......ជស្ស......
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ..............ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី..05...ខែ.....12.....ឆ្នាំ២០១៩
ត.នាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់

លេខ..............
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលថាឡាបរិវ៉ាត់
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ..............ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
អូរស្វាយ,ថ្ងៃទី.......ខែ.......ឆ្នាំ២០១៩
មេឃុំអូរស្វាយ

សូមគោរពជូន
លោកមេឃុំព្រះអូរស្វាយ
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ..............ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ភូមិកោះហិប,ថ្ងៃទី..២០...ខែ..............ឆ្នាំ២០១៩
ប្រធានគណៈកម្មការសហគមន៍នេសាទកោះហិប

លេខ........................ 
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
"ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ........................ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី២៣ ខែ........ឆ្នាំ២០១៩
**ប្រធាន**
**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង**

លៀង_សេង

លេខ........................
បានឃើញ និងគោរពជូន
លោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្ទឹងត្រែង
"ដើម្បីពិនិត្យ និងសម្រួល"
ថ្ងៃ........................ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ស្ទឹងត្រែង,ថ្ងៃទី.........ខែ.........ឆ្នាំ២០១៩
**នាយខណ្ឌរដ្ឋបាលជលផលស្ទឹងត្រែង**

ទុំ នីរ៉ូ

លេខ១៧១ ជ.ក
បានឃើញ និងឯកភាព
ថ្ងៃ........................ខែ..............ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ.........ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អេង ជាសាន